ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

*ថ្ងៃពុធ ៤កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០*
*រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦*

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន ៤២ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ២២២លានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីនៅកម្ពុជា ក្នុងខែមេសា ឆ្នាំ២០២៦

ក្នុងខែមេសា ឆ្នាំ២០២៦ គម្រោងវិនិយោគសរុបដែលត្រូវបានចុះបញ្ជីនៅកម្ពុជាទាំងការចុះបញ្ជីដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) ទាំងការចុះបញ្ជីដោយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត (អ.គ.វ.រ.ខ.) មានចំនួន ៤២គម្រោង ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ២២២លានដុល្លារអាម៉េរិក និងអាចបង្កើតការងារសរុបប្រមាណ ២៤ពាន់កន្លែង។ ក្នុងចំណោមគម្រោងវិនិយោគទាំង ៤២នេះ មានគម្រោងវិនិយោគចំនួន ២៣គម្រោង (ក្រៅតំបន់សេដ្ឋកិច្ចពិសេសចំនួន ១៣គម្រោង, ក្នុងតំបន់សេដ្ឋកិច្ចពិសេសចំនួន ១០គម្រោង) ត្រូវបានចុះបញ្ជីដោយ ក.អ.ក. ក្នុងទំហំទុនវិនិយោគប្រមាណ ១៥៨លានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានប្រមាណ១៨ពាន់កន្លែង។

គម្រោងវិនិយោគដែលមានភាពលេចធ្លោប្រចាំខែមេសា ឆ្នាំ២០២៦ មានដូចខាងក្រោម៖

### ក. ក្រៅតំបន់សេដ្ឋកិច្ចពិសេស៖

**កសិកម្ម និង កសិ-ឧស្សាហកម្ម**

**គម្រោងវិនិយោគបង្កើតកសិដ្ឋានដាំដំណាំឈើហូបផ្លែ និងសាងសង់រោងចក្រកែច្នៃ**

- **ទីតាំង៖** ស្រុកបាណន់ ខេត្តបាត់ដំបង
- **ទំហំទុនវិនិយោគ៖** ប្រមាណ ២០លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ១៧៤កន្លែង។

### ខ. ក្នុងតំបន់សេដ្ឋកិច្ចពិសេស៖

**ឧស្សាហកម្ម**

**គម្រោងវិនិយោគបង្កើតរោងចក្រផលិត និងកែច្នៃប្រេងសម្រាប់សម្បកកង់យានយន្ត និងប្រេងសម្រាប់ផលិតផលកែច្នៃជ័រកៅស៊ូ**

- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស ស៊ីន បាវិត ខេត្តស្វាយរៀង
- **ទំហំទុនវិនិយោគ៖** ប្រមាណ ៩,៦លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៣៥០កន្លែង។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគក្នុង ខែមេសា ឆ្នាំ២០២៦

## ដែលត្រូវបានអនុម័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា

**គម្រោងវិនិយោគ**
**៤២**
គម្រោង

**ទុនវិនិយោគ**
**~២២២**
លានដុល្លារអាមេរិក

**បង្កើតការងារ**
**~២៤ពាន់**
កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាមេរិក)




## ប្រភពទុនវិនិយោគឈានមុខ




## របាយគម្រោងវិនិយោគនៅតាមបណ្តារាជធានី-ខេត្ត




**កំណត់សម្គាល់**
- # ចំនួនគម្រោង
- ១១+
- ៦-១០
- ១-៥
- មិនមាន